# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេចកែសម្រួលលើកទី១
# លើឯកសារអាជ្ញាប័ណ្ណ លេខ ០២៧ ឯអ ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៣
# សម្រាប់លោក គុយ ស៊ួរ

## អាជ្ញាធរអគ្គិសនីកម្ពុជា

-យោងតាមការអនុម័តរបស់សម័យប្រជុំអាជ្ញាធរអគ្គិសនីកម្ពុជា លើកទី៦៤ នៅថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៦

-យោងឯកសារអាជ្ញាប័ណ្ណរួមលេខ ០២៧ ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញឱ្យលោក គុយ ស៊ួរ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៣

-យោងលិខិតស្នើសុំពង្រីកតំបន់ចែកចាយរបស់លោក គុយ ស៊ួរ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០០៥

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០០៥ ដល់ថ្ងៃទី២០ ខែមករា ឆ្នាំ២០០៦

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស.រកម.០២០១.០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

## សម្រេច

**ប្រការ១**

កែសំរួលឯកសារអាជ្ញាប័ណ្ណលេខ ០២៧ឯអ ចុះថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៣ ដែលបានផ្តល់ជូនលោក **គុយ ស៊ួរ** (បន្ទាប់ពីនេះហៅថា "អ្នកកាន់អាជ្ញាប័ណ្ណ") សំរាប់ធ្វើអគ្គិសនីនៅទីប្រជុំជនផ្សារស្នួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាមដោយអនុញ្ញាតឱ្យអ្នកកាន់អាជ្ញាប័ណ្ណពង្រីកតំបន់ចែកចាយអគ្គិសនី បន្ថែមលើតំបន់ចែកចាយអគ្គិសនីដែលមានស្រាប់ (មានបង្ហាញក្នុងផែនទីភ្ជាប់លេខ 027-Kuy Suor- Map-Revised-1) ។

**ប្រការ២**

សេចក្តីសម្រេចនេះ និងឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ត្រូវក្លាយជាផ្នែក មួយនៃអាជ្ញាប័ណ្ណលេខ ០២៧ឯអ ។

**ប្រការ៣**

ឧបសម្ព័ន្ធទី១ នៃអាជ្ញាប័ណ្ណលេខ ០២៧ ឯអ ត្រូវជំនួសដោយឧបសម្ព័ន្ធទី១ កែសម្រួលថ្មីដែលមាន ភ្ជាប់ មក ជាមួយ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃអាជ្ញាប័ណ្ណ លេខ ០២៧ ឯអ ត្រូវ ស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះត្រូវចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើសេចក្តីសម្រេចនេះ ទៅតម្កល់ទុកបន្ថែមនៅតាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ០២៧ ឯអ បានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណ លេខ០២៧ ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មីស្របតាមសេចក្តីសម្រេចនេះ ។

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

ភ្នំពេញ, ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៦

## ឧបសម្ព័ន្ធទី១

## តំបន់អនុញ្ញាតឱ្យចែកចាយអគ្គិសនី

## ធ្វើការកែសម្រួលជាថ្មី ក្នុងសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## លើកទី៦៤ នាថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៦

១- តំបន់អនុញ្ញាត្តឱ្យអ្នកកាន់អាជ្ញាប័ណ្ណធ្វើសេវាកម្មចែកចាយ និងផ្គត់ផ្គង់អគ្គិសនី គឺនៅទីប្រជុំជនផ្សារស្ងួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។

២- តំបន់អនុញ្ញាត្តឱ្យចែកចាយអគ្គិសនីនេះ កំណត់ដោយ " ផែនទីកំណត់ព្រំ ប្រទល់លេខ "027-Kuy Suor- Map-Revised-1" ដែលភ្ជាប់មកជា មួយ ។

៣- ក្នុងក្របខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ ប្រសិនបើអ្នកកាន់អាជ្ញាប័ណ្ណមានបំណង ស្នើសុំពង្រីកតំបន់ចែកចាយថែមទៀត ពេលនោះអ្នកកាន់អាជ្ញាប័ណ្ណត្រូវ រៀបចំឯកសារចាំបាច់នានា ដាក់ស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជាតាមការ កំណត់របស់អាជ្ញាធរ ។ ក្រោយពេលដែលអាជ្ញាធរអគ្គិសនីកម្ពុជាចេញ សេចក្តីសំរេចអនុញ្ញាតឱ្យពង្រីកតំបន់ចែកចាយណាមួយ ឧបសម័ន្ធទី១ នេះ ត្រូវធ្វើការកែសំរួលដោយភ្ជាប់ជាមួយសេចក្តីសម្រេច ឱ្យពង្រីកតំបន់ចែក ចាយនោះ ។

## ឧបសម្ព័ន្ធទី២

## មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ

### ក-មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ

#### រោងម៉ាស៊ីន

១- រោងម៉ាស៊ីនរបស់អ្នកកាន់អាជ្ញាប័ណ្ណ គឺរោងសាងសង់អំពីថ្ម ដំបូលប្រក់ ហ្វីប្រូស៊ីម៉ង់ ទំហំ 24 x 12 ម៉ែត្រ ស្ថិតក្នុងភូមិជើងឡូង ឃុំស្ងួង ស្រុក ត្បូងឃ្មុំ ខេត្តកំពង់ចាម ។

#### លក្ខណៈទូទៅនៃម៉ាស៊ីន

១- អ្នកកាន់អាជ្ញាប័ណ្ណ មានម៉ាស៊ីនភ្លើងចំនួន ០៣គ្រឿង ដែលមានអានុភាព តំឡើងសរុប 740kVA គឺ:

- ម៉ាស៊ីនទី១ : ផលិតនៅប្រទេសចិន, អានុភាពដើម 300kVA
- ម៉ាស៊ីនទី២ : ផលិតនៅប្រទេសចិន, អានុភាពដើម 300kVA
- ម៉ាស៊ីនទី៣ : ម៉ាក Mitsubishi អានុភាពដើម 140kVA

២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងដ្យេសែល ។